**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រ.ក/លេខ ០២.២៣៨/០៧ គជប.អគ្គ.ពស** ភ្នំពេញ ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៧

**សេចក្តីបំភ្លឺ**

**ស្តីពី**

**ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោត**

ទាក់ទងនឹងអត្ថបទជាច្រើនដែលបានចុះផ្សាយតាមសារព័ត៌មាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) សូមធ្វើការបំភ្លឺថា គ.ជ.ប មិនដែលបញ្ជាឱ្យអង្គការកម្ពុជាណាមួយលុបផ្នែកណាមួយនៃការបោះពុម្ពរបស់ខ្លួនឡើយ ហើយ គ.ជ.ប ក៏មិនដែលគំរាមមិនឱ្យអង្គការណាមួយធ្វើការបោះពុម្ពឯកសារដែរ ។

ផ្អែកតាមសំណើររបស់ មជ្ឈមណ្ឌលអភិវឌ្ឍន៍សង្គម (CSD) គ.ជ.ប បានពិនិត្យលើ "សេចក្តីណែនាំអ្នកបោះឆ្នោត " ដែល រួមមានគោលនយោបាយរបស់គណបក្សនយោបាយឈរឈ្មោះបោះឆ្នោតឃុំ សង្កាត់ទាំងអស់ នាពេលខាងមុខនេះ អំពីខ្លឹមសារដែលមានលក្ខណៈបច្ចេកទេសត្រឹមត្រូវ ។

គ.ជ.ប បានជូនដំណឹងដល់ CSD ហើយថា គោលនយោបាយរបស់គណបក្សនយោបាយ រួមមានចំណុចមួយចំនួនដែល អាចចាត់ទុកថា ពុំគោរពតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ក្នុងករណីនេះ គ.ជ.ប សូមឱ្យដកចំណុចនោះ ចេញក្នុងការបោះពុម្ពផ្សាយ ។

ទោះជាយ៉ាងនេះក្តី គ.ជ.ប សូមបញ្ជាក់ថា នៅក្នុងចំណុច ៨.១៥.៦ នៃជំពូកទី ៨ របស់ បទបញ្ជា និងនីតិវិធី របស់ គ.ជ.ប ដែលបានចែងថា "ការបោះពុម្ពផ្សាយ ឬការផ្សព្វផ្សាយសម្ភារៈអប់រំអ្នកបោះឆ្នោតពុំតម្រូវឱ្យមាន សេវាកម្ម ពិនិត្យផ្ទៀងផ្ទាត់/យល់ព្រមចាំបាច់ពី គ.ជ.ប ឡើយ " ។

ហេតុដូច្នេះ CSD នៅតែអាចបោះពុម្ពផ្សាយអត្ថបទរបស់ខ្លួន ប៉ុន្តែអ្នកបោះពុម្ពផ្សាយត្រូវទទួលខុសត្រូវទាំងស្រុង លើខ្លឹមសារនោះ ។